ភ្នំពេញ, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

# កិច្ចពិភាក្សាលើអនុស្សរណៈស្តីពីភាពជាដៃគូរយុទ្ធសាស្ត្រ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និងកំពង់ផែស្វយ័តក្រុងព្រះសីហនុ បានពិភាក្សាលើអនុស្សរណៈស្តីពីភាពជាដៃគូរយុទ្ធសាស្ត្រក្នុងការពង្រឹង និងពង្រីកភាពជាដៃគូរសម្រាប់ការអភិវឌ្ឍកំពង់ផែស្វយ័តក្រុងព្រះសីហនុ។

នាថ្ងៃទី២៤ ខែឧសភា លោក Shigenori OGAWA អគ្គនាយកនៃនាយកដ្ឋានអាស៊ីអាគ្នេយ៍និងប៉ាស៊ីហ្វិក បានមកបំពេញទស្សនៈកិច្ច និងពិភាក្សាលើកិច្ចសហប្រតិបត្តិការនាពេលអនាគតជាមួយកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ ភាគីទាំងពីរបានឯកភាពគ្នាលើចំនុចមួយចំនួនដូចខាងក្រោម ហើយអនុស្សរណៈនេះនឹងត្រូវចុះហត្ថលេខានៅខែមិថុនា ខាងមុខ។

១. JICA នឹងបន្តគាំទ្រដល់កំពង់ផែស្វយ័តក្រុងព្រះស៊ីហានុក្នុងការអភិវឌ្ឍកំពង់ផែ និងការពង្រឹងសមត្ថភាពតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ តាមរយៈការផ្តល់ហិរញ្ញប្បទានឥតសំណង កិច្ចសហប្រតិបត្តិការបច្ចេកទេស និងកម្ចីហិរញ្ញប្បទាន។

២. កំពង់ផែស្វយ័តក្រុងព្រះសីហនុនឹងបន្តពង្រឹងប្រតិបត្តិការ និងការគ្រប់គ្រងកំពង់ផែនិងតំបន់សេដ្ឋកិច្ចពិសេស។

៣. JICA និងកំពង់ផែស្វយ័តក្រុងព្រះសីហនុនឹងបន្តផ្លាស់ប្តូរទស្សនៈវិស័យ និងព័ត៌មាននានាទាក់ទងទៅនឹងការអភិវឌ្ឍកំពង់ផែនិងការរីកចម្រើនផ្នែកភស្តុភាកម្ម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៃប្រទេសកម្ពុជា។

កំពង់ផែស្វយ័តក្រុងព្រះសីហនុ គឺជាកំពុងផែសមុទ្រទឹកជ្រៅអន្តរជាតិតែមួយគត់ក្នុងប្រទេសកម្ពុជាស្ថិតនៅក្នុងខេត្តព្រះសីហនុ ដែលជាច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងរវាងរាជធានីភ្នំពេញនិងខេត្តព្រះសីហនុ។ តំបន់តាមមាត់សមុទ្រត្រូវបានអភិវឌ្ឍជាលំដាប់ និងក្លាយទៅជាតំបន់ឧស្សាហកម្ម ដែលបាននាំមកនូវផលវិជ្ជមានជាច្រើនសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនិងសេដ្ឋកិច្ចប្រទេសកម្ពុជា។ ដើម្បីជម្រុញកម្លាំងនៃការអភិវឌ្ឍនេះ JICA បានផ្តល់ហិរញ្ញប្បទានអភិវឌ្ឍផ្លូវការសម្រាប់គម្រោងស្តារឡើងវិញបន្ទាន់កំពង់ផែស្វយ័តក្រុងព្រះសីហនុនៅឆ្នាំ១៩៩៩ និងគម្រោងពង្រីកបន្ទាន់កំពង់ផែស្វយ័តក្រុងព្រះសីហនុនៅឆ្នាំ២០០៤ ក្នុងគោលដៅលើកកម្ពស់ដំណើរការទំនិញឆ្លងកាត់កំពង់ផែនេះ។

JICA បានចូលរួមទិញភាគហ៊ុនរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលបានដាក់លក់ជាសាធារណៈកាលពីខែមិថុនា ឆ្នាំ២០១៧។

JICA បានផ្ទេរភាគហ៊ុនទាំងអស់របស់ខ្លួនទៅឲ្យក្រុមហ៊ុន Kamigumi Co., Ltd, កាលពីខែឧសភា ឆ្នាំ២០១៩ (https://www.jica.go.jp/english/news/press/2019/20190524_10_en.html) ប៉ុន្តែ JICA និងក្រុមហ៊ុនជប៉ុនទាំងអស់នឹងនៅតែបន្តចែករំលែកបទពិសោធន៍គ្រប់គ្រងកំពុងផែ និងកិច្ចសហប្រតិបត្តិការផ្សេងៗសម្រាប់ការអភិវឌ្ឍកំពង់ផែស្វយ័តក្រុងព្រះសីហនុនាពេលអនាគត។

*សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងទៅលោក ស៊ុន វាសនា មន្ត្រីផ្នែកទំនាក់ទំនងសាធារណៈនៃការិយាល័យ JICA ប្រចាំនៅកម្ពុជា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៦៧៣/៤ ឬ ០១២ ៨៥១ ៨៤៤ អ៊ីម៉ែល* Soun-Veasna@jica.go.jp.